ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 31-Jan-2014, 15:20
CMS/CFO: Sann Rada

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៤

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

**សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដីលោក ខៀវ សំផន**
**ពាក់ព័ន្ធនឹងវិសាលភាពនៃសំណុំរឿង ០០២/០២**

---

<u>ដាក់ដោយ</u>៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

មេធាវី Arthur VERCKEN

<u>ដាក់ជូន</u>៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ូរ ឧត្ដរា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Soumeya MEDJEBEUR

កញ្ញា អ៊ុច ស្រីផាត

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្តី លោក នួន ជា**

# សូមគោរពអង្គជំនុំជម្រះសាលាដំបូង

១. នៅថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") បានផ្ញើជូនភាគីនូវផែនការងារសម្រាប់សំណុំរឿង ០០២ វគ្គទី ២ (០០២/០២)[1]។ អង្គជំនុំជម្រះបានស្នើឲ្យភាគីដាក់សារណាជាលាយលក្ខណ៍អក្សរអំពីវិសាលភាពនៃសំណុំរឿង ០០២/០២ ត្រឹមថ្ងៃទី ៣១ ខែមករា ឆ្នាំ២០១៤[2] ហើយបានប្រកាសថា បន្ទាប់មកទៀត អង្គជំនុំជម្រះនឹងកំណត់ *"កាលបរិច្ឆេទដូចខាងក្រោមនេះ"* ដោយរួមបញ្ចូលការ *"ផ្តល់ឱកាសឲ្យភាគីនានា ដើម្បីដាក់សារណាជាលាយលក្ខណ៍អក្សរ ឬធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់អំពីអង្គហេតុ/បទចោទនានា ដែលមិនត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿង ០០២/០២"*[3]។

២. មេធាវីការពារក្តីលោក ខៀវ សំផន ("មេធាវីការពារក្តី") សូមជំទាស់នឹងការបំបែកកិច្ចដំណើរការនីតិវិធីជាថ្មី ក្នុងចំណោមអង្គហេតុនៅសេសសល់ ដែលត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង ០០២នេះ។ មេធាវីការពារក្តីក៏ជំទាស់ផងដែរនឹងរបៀបធ្វើការរបស់អង្គជំនុំជម្រះ ដែលមើលស្រាលទៅលើគោលការណ៍ជាមូលដ្ឋាននៃភាពអាចព្យាករណ៍បាន និងសុវត្ថិភាពគតិយុត្តិ។

## I- <u>ការបដិសេធការបំបែកកិច្ចដំណើរការនីតិវិធីជាថ្មី</u>

៣. ជាថ្មីម្តងទៀត ការបំបែកកិច្ចដំណើរការនីតិវិធីជាថ្មី នៅក្នុងសំណុំរឿង ០០២ ផ្ទុយនឹងសិទ្ធិរបស់លោក ខៀវ សំផន ក្នុងការទទួលបានការជំនុំជម្រះ ដោយមិនអូសបន្លាយពេលវេលា និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

៤. ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលបានផ្តល់សុពលភាព ដល់បំបែកកិច្ចដំណើរការនីតិវិធីចុងក្រោយរបស់អង្គជំនុំជម្រះសាលាដំបូងក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលបានរៀបរាប់យ៉ាងពិស្តារអំពីគុណវិបត្តិដែលបង្កឡើងដោយការបំបែកការជំនុំជម្រះក្តីបែបនេះ។

---

[1] ផែនការការងាររបស់អង្គជំនុំជម្រះសាលាដំបូងសម្រាប់សំណុំរឿង ០០២/០២ និងការកំណត់កាលបរិច្ឆេទនៃការដាក់ឯកសារនាពេលខាងមុខ អនុស្សរណៈ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៣ ឯកសារ **E301/5** ("ផែនការការងារ **E301/5**")។

[2] ផែនការការងារ **E301/5** កថាខណ្ឌ ៥។

[3] ផែនការការងារ **E301/5** កថាខណ្ឌ ៨។

៥. ជាក់ស្តែង អង្គជំនុំជម្រះតុលាការកំពូលបានរំឭកថា សេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី *“គឺត្រូវជាប់ពាក់ព័ន្ធទៅនឹងការធ្វើឱ្យមានតុល្យភាពនូវអត្ថប្រយោជន៍ផ្សេងៗគ្នាដែលស្របច្បាប់ ដោយធ្វើការប្រៀបធៀបរវាងផលប្រយោជន៍ និងគុណវិបត្តិនៃការបើកការជំនុំជម្រះតែមួយលើបទចោទទាំងអស់ ដែលមានក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលខុសប្លែកពីផលប្រយោជន៍ និងគុណវិបត្តិនៃការបើកការជំនុំជម្រះច្រើនលើបទចោទដូចៗគ្នា”*[4]។ អង្គជំនុំជម្រះតុលាការកំពូលក៏បានរំឭកផងដែរថា កត្តាមួយចំនួនដែលត្រូវបាន *“យកមកពិចារណា ក្នុងចំណោមកត្តាជាច្រើនរួមមាន ការធ្វើឱ្យប៉ះពាល់ជាសក្តានុពលដល់សិទ្ធិរបស់ជនជាប់ចោទ ប្រសិទ្ធភាព និងភាពអាចចាត់ចែងបាននៃកិច្ចដំណើការនីតិវិធី គោលបំណងជៀសវាងភាពពុំស៊ីសង្វាក់គ្នារវាងការជំនុំជម្រះដាច់ដោយឡែកពីគ្នា និងការទទួលបន្ទុកទៅលើសាក្សី”*[5]។

៦. អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា *“ការធ្វើឱ្យប៉ះពាល់ជាសក្តានុពលដល់សិទ្ធិរបស់ជនជាប់ចោទ ត្រូវបានយកមកពិចារណាជាចម្បង ចំពោះសិទ្ធិទទួលបានការជំនុំជម្រះដោយមិនមានការអូសបន្លាយពេលវេលា”* ដោយចៅក្រមពិចារណាឃើញជាអាទិ៍ថា *“សវនាការពីរបន្តបន្ទាប់គ្នា [...] ពិតជាត្រូវការចំណាយពេលវេលាច្រើនជាងសវនាការតែមួយ ដោយជៀសមិនរួចឡើយ”*[6]។

៧. លោក ខៀវ សំផន មិនបានជំទាស់ទៅនឹងការបំបែកកិច្ចដំណើរការនីតិវិធីលើកទីមួយរបស់អង្គជំនុំជម្រះ គឺដោយសារតែនៅពេលនោះ គាត់យល់ឃើញថា គេនឹងគោរពសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះ ដោយមិនមានការអូសបន្លាយពេលវេលា និងសិទ្ធិក្នុងការទទួលបានការជំនុំជម្រះប្រកបដោយភាពយុត្តិធម៌។

៨. ក៏ប៉ុន្តែ អ្វីៗផ្ទុយពីការគិតរបស់គាត់។

៩. ផ្ទុយទៅវិញ ភាពយឺតយ៉ាវ និងការលំបាកផ្នែកនីតិវិធី និងគតិយុត្តិ ដែលបានចោទឡើងក្នុងសំណុំរឿង ០០២ វគ្គទី ១ (០០២/០១) បានឈានដល់កម្រិតធ្ងន់ធ្ងរបំផុត រហូតដល់ថ្នាក់មេធាវីការពារក្តី

---

[4] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ **E284/4/8** (“សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងការបំបែកកិច្ចដំណើរការនីតិវិធី **E284/4/8**”) កថាខណ្ឌ ៣៧។

[5] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងការបំបែកកិច្ចដំណើរការនីតិវិធី **E284/4/8** កថាខណ្ឌ ៣៨។

[6] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងការបំបែកកិច្ចដំណើរការនីតិវិធី **E284/4/8** កថាខណ្ឌ ៣៨។

បានស្នើសុំឲ្យបញ្ចប់កិច្ចដំណើរការនីតិវិធីភ្លាម[7]។

១០. ការមិនកំណត់វិសាលភាពនៃសំណុំរឿង ០០២ វគ្គទី ១ (០០២/០១) ឲ្យបានច្បាស់លាស់ អវត្តមានក្របខ័ណ្ឌច្បាប់អនុវត្តឲ្យបានច្បាស់លាស់លើការបង្ហាញភ័ស្តុតាង និងភាពស្រពេចស្រពិលទាំងស្រុងទៅលើការជ្រើសរើសធាតុផ្សំអង្គហេតុ ដែលអាចត្រូវបានយកមកពិចារណា សម្រាប់ការកំណត់ទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ និងការកំណត់ប្រភេទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បាននាំឲ្យមានការពិភាក្សាផ្នែកនីតិវិធី និងបណ្តាលឲ្យមានការរំលោភសិទ្ធិរបស់លោក ខៀវ សំផន រួចទៅហើយ។ ភាគីនានាបានធ្វើសំណើសុំការបំភ្លឺជាច្រើន ប៉ុន្តែរហូតមកទល់ថ្ងៃនេះមិនទាន់ទទួលបានចម្លើយណាមួយច្បាស់លាស់នៅឡើយទេ[8]។

១១. អាស្រ័យហេតុនេះ សំអាងហេតុដែលបានលើកឡើងនៅក្នុងសំណើសុំឲ្យបញ្ឈប់កិច្ចដំណើរការនីតិវិធីភ្លាមៗ នៅតែមានសុពលភាពដដែល។

១២. បរិបទនេះបានបង្កលក្ខណៈងាយស្រួលដល់ចេតនាពង្រីកវិសាលភាពឥតងាករេរបស់សហព្រះរាជអាជ្ញា។ ឧទាហរណ៍ នៅចុងបញ្ចប់នៃសំណុំរឿង ០០២/០១ សហព្រះរាជអាជ្ញា (គាំទ្រផ្ទាល់មាត់ដោយដើមបណ្តឹងរដ្ឋប្បវេណី) ថែមទាំងបានសម្តែងអភិមានៈ រហូតដល់ថ្នាក់អះអាងអំពីអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួមជាលក្ខណៈប្រព័ន្ធ (ពាក់ព័ន្ធនឹងការចូលរួមរបស់ជនជាប់ចោទក្នុងប្រព័ន្ធនៃការធ្វើបាប ក្នុងជំរំ ឬមន្ទីរឃុំឃាំង) ដែលផែនការឧក្រិដ្ឋរួមទំនងជាមានគោលដៅដាក់ប្រទេសកម្ពុជាទាំងមូលឲ្យស្ថិតក្នុងទាសភាព និងកម្ទេចខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា។ ក៏ប៉ុន្តែ ច្បាស់ណាស់ សហករណ៍ និងមន្ទីរសន្តិសុខ ត្រូវបានដកចេញពីវិសាលភាពនៃសំណុំរឿង ០០២/០១ !

---

[7] សំណើបន្ទាន់របស់មេធាវីការពារក្តីលោក ខៀវ សំផន សុំឲ្យបញ្ឈប់កិច្ចដំណើរការនីតិវិធីភ្លាម ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E275/2/1/1**។

[8] ឧទាហរណ៍ សូមមើលសំណើសុំការបំភ្លឺពីរចុងក្រោយ ដែលបានដាក់ក្រោយពេលបញ្ចប់ការពិភាក្សាដេញដោលលើអង្គសេចក្តីក្នុងពេលកំពុងសរសេរសារណាបញ្ចប់ការពិភាក្សាដេញដោល៖ សំណើរបស់ [សហព្រះរាជអាជ្ញា] សុំការបំភ្លឺអំពីការរកឃើញទាក់ទងនឹងសហឧក្រិដ្ឋកម្មរួម ដូចបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E284/5,** សំណើបន្ទាន់ [របស់មេធាវីការពារក្តីលោក ខៀវ សំផន] សុំឲ្យបំភ្លឺអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការជំទាស់ទៅលើភាពអាចទទួលយកបាននៃកំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ និងសុំលើកពេលដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៣ ឯកសារ **E299/1**។

១៣. ថ្មីៗនេះទៀត សហព្រះរាជអាជ្ញាបានស្នើឲ្យអង្គជំនុំជម្រះធ្វើហួសពីដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី និងវិធានគតិយុត្តិជាធរមានទៅទៀត ដោយបានស្នើសុំឲ្យអង្គជំនុំជម្រះសម្រេចថា ភ័ស្តុតាងទាំងអស់ដែលបានដាក់ឲ្យពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០១ នឹងត្រូវទទួលយកក្នុងសំណុំរឿង ០០២/០២ ជាស្វ័យប្រវត្តិ[9]។

១៤. ដូច្នេះ ថ្ងៃនេះ មេធាវីការពារក្តីស្នើសុំឲ្យអង្គជំនុំជម្រះឈប់បំបែករឿងក្តីនេះតទៅទៀត និងសុំឲ្យអង្គជំនុំជម្រះវិនិច្ឆ័យជនជាប់ចោទ លើបទចោទទាំងឡាយដែលនៅសេសសល់។ ដំណោះស្រាយនេះមិនល្អឥតខ្ចោះនោះទេ ប៉ុន្តែ ជាដំណោះស្រាយល្អបំផុត ដែលអង្គជំនុំជម្រះអាចធ្វើបាន។ មេធាវីការពារក្តីមិនពេញចិត្តនឹងដំណោះស្រាយនេះទេ ប៉ុន្តែ នេះជាសំណើតែមួយគត់ ដែលខ្លួនអាចធ្វើបានយ៉ាងសមរម្យ ពីព្រោះវាជាមធ្យោបាយតែមួយគត់ក្នុងការមិនបន្ថែមការរំលោភបំពានថ្មីៗទៀតលើសិទ្ធិរបស់ជនជាប់ចោទ ទៅលើការរំលោភបំពានដែលបានប្រព្រឹត្តកន្លងរួចមកហើយ និងដែលអាចជួសជុលបាន តែតាមរយៈការដោះលែងជនជាប់ចោទ ដោយគ្មានល័ក្ខខ័ណ្ឌ ប៉ុណ្ណោះ។

១៥. ជាអកុសល មេធាវីការពារក្តីសង្កេតឃើញថា អង្គជំនុំជម្រះត្រៀមខ្លួនប្រព្រឹត្តកំហុសដដែលៗដូចកាលពីអតីតកាលដែរ ដោយប្រមាថជាថ្មីម្តងទៀតលើគោលការណ៍នៃភាពអាចព្យាករណ៍បាន និងសុវត្ថិភាពគតិយុត្តិ។

## II. ការបដិសេធចំពោះភាពមិនអាចព្យាករណ៍បាន និងអសុវត្ថិភាពគតិយុត្តិ

១៦. ការវិភាគទៅលើផែនការការងារផ្តល់ដោយអង្គជំនុំជម្រះសម្រាប់សំណុំរឿង ០០២/០២ បង្ហាញឲ្យឃើញថា អង្គជំនុំជម្រះបានត្រៀមខ្លួនរួចហើយ ដើម្បីធ្វើការបំបែកសំណុំរឿងថ្មីមួយទៀត។ ជាក់ស្តែង អង្គជំនុំជម្រះ បានស្នើឲ្យភាគីទាំងអស់ ដាក់សំអាងហេតុស្តីពីវិសាលភាពនៃការជំនុំជម្រះក្តីដំណាក់កាលទីពីរ ព្រមទាំងប្រកាសថា អង្គជំនុំជម្រះនឹងស្តាប់នាពេលក្រោយទៀតនូវសំអាងហេតុរបស់ភាគី ស្តីពីស្ថានភាពនៃអង្គហេតុកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ "*ដែលមិនទាន់ដាក់បញ្ចូលទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្តីទាំងពីរដំណាក់កាល*"។ ដូចនេះ អង្គជំនុំ

[9] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្តីពីការប្រើប្រាស់ភ័ស្តុតាង និងនីតិវិធីក្នុងការកោះហៅសាក្សីជាថ្មី ពីសំណុំរឿង ០០២/០១ ទៅក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤ ឯកសារ **E302**, ចម្លើយរបស់ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ទៅនឹង "សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្តីពីការប្រើប្រាស់ភ័ស្តុតាង និងនីតិវិធីក្នុងការកោះហៅសាក្សីជាថ្មី ពីសំណុំរឿង ០០២/០១ ទៅក្នុងសំណុំរឿង ០០២/០២" ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៤ ឯកសារ **E302/1**។

ជម្រះមានចេតនាច្បាស់ក្រឡែតណាស់ ពោលគឺវានឹងមានការបំបែកសំណុំរឿងថ្មីមួយទៀត និងមានការជំនុំជម្រះក្តី វគ្គទីបី ជាយថាហេតុ។

១៧. ចំណាត់ការបែបនេះ ជាទង្វើប្រាសចាកពីគោលការណ៍ជាសារវ័ន្តនៃភាពអាចគ្រោងទុកជាមុនបាន និងសុវត្ថិភាពគតិយុត្តិ ព្រមទាំងបានទទួលរងនូវការរិះគន់រួចមកហើយដែរ ពីសំណាក់អង្គជំនុំជម្រះតុលាការកំពូល[10]។ ក្រុមមេធាវីការពារប្រកាន់ជំហរមិនងាករេថា គេត្រូវតែគោរពតាមគោលការណ៍ទាំងនេះ។ ការមិនគោរពគោលការណ៍នេះជាការមិនផ្តល់សុពលភាព និងទំនុកចិត្តដល់រាល់ដំណើរការស្វែងរកយុត្តិធម៌ ទោះបីចំនួនជនរងគ្រោះ និងកម្រិតធ្ងន់ធ្ងរនៃអង្គហេតុដែលត្រូវវិនិច្ឆ័យមានទំហំប៉ុនណាក៏ដោយ។

១៨. ក្រៅពីគោលជំហរដាច់ខាតមិនងាករេតាមគោលការណ៍នេះ ក្រុមមេធាវីការពារក្តីយល់ឃើញថា ខ្លួនមិនមែនជាអ្នកដែលអាចជ្រើសរើស "តាមចំណង់" ក្នុងចំណោមអង្គហេតុនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដូចជម្រើសនៅក្នុង "បញ្ជីរាយមុខម្ហូប" នោះទេ។ រឿងនេះរឹតតែមានប្រយោជន៍តិចជាងការដែលលោក ខៀវ សំផន ប្រឆាំងនឹងរាល់បទចោទទាំងអស់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទៅទៀត។

១៩. ផ្ទុយទៅវិញ អ្វីដែលប្រាកដនោះ គឺថា នៅចំពោះមុខសហព្រះរាជអាជ្ញាដែលគាំទ្រទម្រង់ទីពីរ នៃសហឧក្រិដ្ឋកម្មរួម និងប្រើប្រាស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូល ដើម្បីធ្វើចំណាត់ថ្នាក់ធាតុផ្សំនៃជំពូករួម ការបំបែកកិច្ចដំណើរការនីតិវិធីណាមួយមិនធ្លាប់ធ្វើទៅបានទេ ហើយក៏លែងធ្វើទៅបានដែរនៅពេលនេះ។ ជំហររបស់សហព្រះរាជអាជ្ញាបានធ្វើឱ្យខូច ហើយក៏នឹងធ្វើឱ្យខូចទ្រង់ទ្រាយរាល់ការជំនុំជម្រះក្តី ទោះធ្វើជាប៉ុន្មានវគ្គក៏ដោយ។ ព្រោះថា ចាប់តាំងពីការជំនុំជម្រះក្តីវគ្គ

---

[10] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ **E163/5/1/13** កថាខណ្ឌ ៤៧, ៤៨ និង ៥០, សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ សេចក្តីសង្ខេបនៃសំអាងហេតុ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ **E284/4/7** កថាខណ្ឌ ៨ ដល់ ១០, សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើសំណើសុំដោះលែង ខៀវ សំផន ឱ្យនៅក្រៅឃុំជាបន្ទាន់ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E275/2/3** កថាខណ្ឌ ៤៨, សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងការបំបែកកិច្ចដំណើរការនីតិវិធី **E284/4/8** កថាខណ្ឌ ៦៨ និង ៦៩។ សូមមើលផងដែរ៖ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំការបញ្ជាក់បំភ្លឺ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E284/2/1/2** កថាខណ្ឌ ៦។

ទីមួយមក សហព្រះរាជអាជ្ញាបានធ្វើសំអាងហេតុរបស់ខ្លួន ដោយផ្អែកលើព្រឹត្តិការណ៍សរុបទាំងមូលដែលទំនងជាបានកើតឡើងក្នុងប្រទេសកម្ពុជា ក្នុងចន្លោះឆ្នាំ ១៩៧៥ និង១៩៧៩ ដូច្នេះ វាពិតជារឿងក្តីតែមួយគត់ ដែលគួរតែទទួលបានការជំនុំជម្រះទាក់ទងនឹងព្រឹត្តិការណ៍សរុបទាំងមូលដែលទំនងជាបានកើតឡើងនេះ។ នេះជាប្រការមួយដែលលែងអាចធ្វើទៅរួចហើយ។ ដូច្នេះ គេត្រូវដោះលែងជនជាប់ចោទ។

២០. ទោះជាយ៉ាងដូច្នេះក្តី ក្នុងករណីអង្គជំនុំជម្រះសម្រេចចិត្តធ្វើមិនដឹងមិនឮចំពោះភាពសមហេតុផល និងនៅតែសម្រេចធ្វើការផ្តន្ទាទោស ក្រុមមេធាវីការពារក្តីនឹងប្រើប្រាស់រាល់មធ្យោបាយតទល់ភ្លាមៗ ដើម្បីធ្វើមោឃភាពសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ។

២១. រឿងនេះដូចគ្នាបេះបិទនឹងបញ្ហានៃការបញ្ចប់ជាយថាហេតុនៃកិច្ចដំណើរការនីតិវិធីនានា ទាក់ទងនឹងអង្គហេតុដែលប្រហែលជាមិនជ្រើសរើសយកសម្រាប់សំណុំរឿង ០០២/០២។ ក្រុមមេធាវីការពារក្តីសូមជំទាស់រាល់ការបញ្ចប់ជាយថាហេតុនៃកិច្ចដំណើរការនីតិវិធីនានានេះ ដោយហេតុថា សហព្រះរាជអាជ្ញា ដែលទទួលបានទំនុកចិត្តតាមរយៈអនុសាសន៍ និងទង្វើខុសឆ្គងរបស់អង្គជំនុំជម្រះ បានដាក់បញ្ចូល សាជាថ្មីទៅក្នុងសំអាងហេតុរបស់ខ្លួននូវធាតុផ្សំសរុបទាំងមូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ដូច្នេះ បើទទួលថា អង្គហេតុមួយចំនួនត្រូវបានបោះបង់ចោល នោះក៏ដូចលោក ខៀវ សំផន ទទួលថា លែងអាចការពារខ្លួនប្រឆាំងនឹងការចោទប្រកាន់ផ្សេងៗ ដែលបានធ្វើមកលើរូបលោកដែរ។ នេះគឺជារឿងដែលមិនអាចទទួលយកបានទេ។

២២. ទាក់ទងនឹងបញ្ហានៃការបញ្ចប់កិច្ចដំណើរការនីតិវិធីនេះ វាច្បាស់ណាស់ថា ហានិភ័យនៃទង្វើខុសឆ្គងបន្ថែមទៀតកាន់តែមានកម្រិតខ្ពស់ខ្លាំង។ ក៏ប៉ុន្តែ អង្គជំនុំជម្រះ និងសហព្រះរាជអាជ្ញាបានផ្តល់ចំណាប់អារម្មណ៍ខ្ពស់ក្នុងការព្រមព្រៀងគ្នា ប្រព្រឹត្តនូវការរំលោភបំពានបន្ថែមនូវសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទទាំងអស់ ក្នុងការទទួលបាននូវពត៌មានស្តីពីបន្ទុកនៃចោទប្រកាន់មកលើខ្លួន និងទទួលបានពេលវេលា និងមធ្យោបាយចាំបាច់សម្រាប់ត្រៀមរៀបចំការពារខ្លួន[11]។

[11] សារៈសំខាន់នៃសិទ្ធិទាំងនេះត្រូវបានអង្គជំនុំជម្រះតុលាការកំពូលរំឭកដល់អង្គជំនុំជម្រះសាលាដំបូង៖ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំការបញ្ជាក់បំភ្លឺ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E284/2/1/2** កថាខណ្ឌ ៦ និងកំណត់សម្គាល់ជើងទំព័រ ១៣។

២៣. ករណីនេះបានកើតមាននៅក្នុងកិច្ចប្រជុំរៀបចំសវនាការរៀបចំឡើងដោយអង្គជំនុំជម្រះ នាខែ ធ្នូ ឆ្នាំ ២០១៣។ នាឱកាសនោះ ក្រោយពីបានគូសបញ្ជាក់ពីភាពស្មុគ្រស្មាញនៃបញ្ហា និងភាពចាំបាច់ឲ្យមានកិច្ចពិភាក្សាមួយ "*ហ្មត់ចត់*" លើប្រធានបទនេះ លោកចៅក្រម LAVERGNE បានស្នើសុំថា កិច្ចពិភាក្សានេះគួរតែធ្វើ "*នៅពេលក្រោយ*" ដោយលោកប្រកាសថា ៖ "*ដោយសារអាទិភាពចំពោះមុខ ជាបឋម យើងគួរសម្រេចពីវិសាលភាពនៃការជំនុំជម្រះ និងសម្រេចដោយថាហេតុពីការបំបែកសំណុំរឿង*"[12]។

២៤. ចម្លើយរបស់សហព្រះរាជអាជ្ញាចំពោះសំណើនេះ គឺមិនមានអ្វីភ្ញាក់ផ្អើលនោះទេ៖ "*យើងយល់ស្របទាំងស្រុង។ ការជំនុំជម្រះនឹងអាចប្រព្រឹត្តទៅនាពេលខាងមុខ បន្ទាប់ពីវិសាលភាពត្រូវបានកំណត់រួចហើយ*"[13]។

២៥. ជំហរប្រកាន់យកដោយសមាជិកនៃអង្គជំនុំជម្រះមួយរូប និងចម្លើយរបស់សហព្រះរាជអាជ្ញា ស្តែងឲ្យឃើញថា ក្នុងករណីចាំបាច់ បញ្ហាទាំងទងនឹងស្ថានភាពអង្គហេតុដែលមិនបានដាក់បញ្ចូលក្នុងសំណុំរឿង ០០២/០២ អាចនឹងក្លាយទៅជាឱកាសបន្ថែមមួយទៀត ក្នុងការរំលោភបំពានលើសិទ្ធិជនជាប់ចោទ។ ព្រោះថា ក្នុងករណីអង្គជំនុំជម្រះសម្រេចបំបែកសំណុំរឿងថ្មីមួយទៀត និងទុកលទ្ធភាពសម្រេចនាពេលក្រោយ អំពីការបញ្ចប់កិច្ចដំណើរការនីតិវិធី ឬនឹងមានការជំនុំជម្រះវគ្គទីបី នោះមានន័យថា លោក ខៀវ សំផន នឹងនៅតែមិនអាចដឹងអស់រយៈពេលច្រើនឆ្នាំទៀត ពីអង្គហេតុជាក់លាក់ដែលចោទប្រកាន់លើរូបលោកនៅចំពោះមុខច្បាប់។

២៦. តើវាពិតជាមានប្រយោជន៍ឬទេ ដែលត្រូវរំលឹកថា អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចកាលពីពេលថ្មីៗនេះថា អង្គជំនុំជម្រះ "*មានកាតព្វកិច្ចសម្រេចពីបញ្ហានានាដែលប្តឹងមកខ្លួន*" និង "*វិនិច្ឆ័យជាស្ថាពរលើបណ្តឹងទាំងនោះ*"[14]?។ ប្រហែលជាមិនមានប្រយោជន៍ទេ។

---

[12] ប្រតិចារឹកសវនាការ ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៣ ឯកសារ **E1/238.2** ទំព័រ ៣៩ បន្ទាត់ ៧-១២ ប្រហែលម៉ោង [11.14.04]។

[13] ប្រតិចារឹកសវនាការ ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៣ ឯកសារ **E1/238.2** ទំព័រ ៣៩ បន្ទាត់ ១៥-១៦ ប្រហែលម៉ោង [11.14.04]។

[14] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងការបំបែកកិច្ចដំណើរការនីតិវិធី **E284/4/8** កថាខណ្ឌ ៦២ និងកំណត់សម្គាល់ជើងទំព័រ ១៧២។

២៧. ជាក់ស្តែង បើសិនជារាល់អង្គហេតុទាំងអស់ដែលមិនទាន់បានយកមកជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ក៏មិនត្រូវបានយកមកជម្រះក្នុងសំណុំរឿង ០០២/០២ នោះសហព្រះរាជអាជ្ញា នឹងមានឱកាសទូលំទូលាយមួយ នាពេលក្រោយ ដើម្បីស្នើសុំឲ្យបង្កើតការជំនុំជម្រះ វគ្គទីបី នៅពេលដែលជនជាប់ចោទណាម្នាក់យ៉ាងតិច នៅតែអាចមានសម្បទាសម្រាប់ទទួលការវិនិច្ឆ័យក្តី ហើយអង្គជំនុំជម្រះវិសាមញ្ញ នៅតែទទួលបានការឧបត្ថម្ភថវិការ។

២៨. អាស្រ័យដូចនេះ ជម្រើសតែមួយគត់សម្រាប់អង្គជំនុំជម្រះគឺត្រូវជំនុំជម្រះលើអង្គហេតុទាំងអស់ ដែលនៅសល់។ លើកលែងតែមានការសម្រេចដោះលែងជនជាប់ចោទក្នុងសំណុំរឿង ០០២/០១ ពុំនោះសោតទេ ដំណោះស្រាយនេះនឹងមិនអាចជួសជុលព្យសនកម្មដ៏ធំធេង ដែលជនជាប់ចោទ បានទទួលរងពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទីមួយ និងពីការដែលសហព្រះរាជអាជ្ញា បានបដិសេធមិនគោរពតាមវិធានទាំងឡាយ ដែលចេញមកពីការបំបែកកិច្ចដំណើរការនីតិវិធីនេះ។

២៩. ជាទីបញ្ចប់ យើងស្នើសុំដល់អង្គជំនុំជម្រះមេត្តាបដិសេធចោលនូវរាល់លេសដ៏ពុតត្បុត និងអរូបី ក្រោមរូបភាពនៃការជំនុំជម្រះក្តីជាបន្ទាន់ ដោយសារវ័យជរាភាព ឬស្ថានភាពសុខភាពរបស់ជន ជាប់ចោទ។ ជាក់ស្តែង ដោយពិនិត្យមើលថេរវេលារង់ចាំសេចក្តីសម្រេចលើនីតិវិធីរបស់អង្គជំនុំ ជម្រះតុលាការកំពូល វាអាចថា៖ ១) ជនជាប់ចោទនឹងស្លាប់ដោយមិនទាន់បានជំនុំជម្រះជាស្ថាពរ ឬអាចថា ២) តាមទិដ្ឋភាពជាក់ស្តែង ដំណោះស្រាយស្នើឡើងដោយក្រុមមេធាវីការពារក្តី នាពេលនេះ អាក្រក់តិចជាងគេបំផុត និងលឿនជាងគេបំផុត...

៣០. **អាស្រ័យហេតុនេះ** មេធាវីការពារក្តីលោក ខៀវ សំផន ស្នើសុំអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

- **ប្រកាស** និង **សម្រេច** ថា សំណុំរឿង ០០២/០២ នឹងផ្តោតទៅលើបទចោទទាំងអស់នៅក្នុង ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមិនទាន់បានពិនិត្យនៅក្នុងសំណុំរឿង ០០២/០១។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន | រាជធានីភ្នំពេញ | |
| | មេធាវី Anta GUISSÉ | ទីក្រុងប៉ារីស | |
| | មេធាវី Arthur VERCKEN | ទីក្រុងប៉ារីស | |